# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Apr-2015, 13:25
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ** អមដោយឧបសម្ព័ន្ធសម្ងាត់បំផុត៦

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

## ការដាក់បង្ហាញឯកសារមួយចំនួនរបស់សហព្រះរាជអាជ្ញាអន្តរជាតិពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤-D193/21

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**

លោក Nicholas KOUMJIAN

**ចម្លងជូន:**

លោកស្រី ជា លាង

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark B. HARMON

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក ពេជ អង្គ

លោកស្រី Marie GUIRAUD

**ចម្លងជូន:**

**ជនជាប់ចោទ**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**

លោក សុន អរុណ

លោក Victor KOPPE

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

**មេធាវីប្រចាំការ:**

លោកស្រី ទូច វលក្ស

លោក Calvin SAUNDERS

## I. ការដាក់បង្ហាញ

1. សហព្រះរាជអាជ្ញាអន្តរជាតិ (“សហព្រះរាជអាជ្ញា”) សូមដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារពាក់ព័ន្ធចំនួន៥៣ ដែលបានទទួលយករួចហើយនៅក្នុងសំណុំរឿង០០៤ ដែលពាក់ព័ន្ធទៅនឹងសវនាការក្នុងសំណុំរឿង០០២/០២ (“សម្ភារៈ”)។ ឯកសារទាំងអស់នេះសុទ្ធតែបានកំណត់អត្តសញ្ញាណនៅក្នុង **ឧបសម្ព័ន្ធ ១** សម្ងាត់បំផុត។

2. សហព្រះរាជអាជ្ញា សូមស្នើការអនុញ្ញាតដាក់បង្ហាញសម្ភារៈទាំងឡាយ ដែលបានបញ្ចូលនៅក្នុងសំណើសុំដាក់បង្ហាញនេះ តាមរយៈសំណើសុំចំនួនពីរ(សំណើទាំងពីររួមគ្នាហៅថា“សំណើ”) ដែលបានដាក់ជូនសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥[1] និងថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០១៥[2]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុញ្ញាតតាមសំណើ ទាក់ទងនឹងឯកសារដែលបច្ចុប្បន្នកំពុងដាក់បង្ហាញនៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៥[3] ដែលសេចក្តីសម្រេចនោះ ត្រូវបានចែកជូនដល់អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃចេញ។ ឯកសារចំនួនប្រាំដែលបានបញ្ចូលនៅក្នុងសំណើសុំទាំងនេះ ក៏ទទួលបានការអនុញ្ញាតឲ្យដាក់បង្ហាញដែរ តែក្នុងទម្រង់កោសលុបប៉ុណ្ណោះ។ ឯកសារទាំងនោះបានដាក់ភ្ជាប់ទៅជាមួយសំណៅបកប្រែជាភាសាអង់គ្លេសជា **ឧបសម្ព័ន្ធ ២, ៣, ៤, ៥** និង **៦ សម្ងាត់បំផុត**។

3. អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា កាតព្វកិច្ចដើម្បីបង្ហាញសម្ភារៈពាក់ព័ន្ធ ទោះជាដាក់បន្ទុក ឬដោះបន្ទុកក្តី គឺជាកាតព្វកិច្ចមួយដែលអង្គជំនុំជម្រះសាលាដំបូងមាន ដូចគ្នានឹងជនជាប់ចោទដែរ ដោយហេតុថា “ជាប្រយោជន៍ដែលនាំដល់ការស្វែងរកការពិត ដែលអង្គជំនុំជម្រះមានសិទ្ធិចូល

[1] សំណុំរឿង 004-**D193/17** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយនៃសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការលើសំណុំរឿង ០០២/០២, ១៣ មីនា ២០១៥។

[2] សំណុំរឿង 004-**D193/20** សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារក្នុងសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការលើសំណុំរឿង ០០២/០២, ២៣ មីនា ២០១៥។

[3] សំណុំរឿង 004-**D193/21** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបង្ហាញឯកសារសំណុំរឿង០០២ ឯកសារ D193/17 និង D193/20, ៦ មេសា ២០១៥។

ពិនិត្យមើលឯកសារទាំងនេះ”[4]។ ជាងនេះទៀត អង្គជំនុំជម្រះនេះធ្លាប់បានសម្រេចពីមុនថា “វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង ដាក់កាតព្វកិច្ចជាបន្តបន្ទាប់ទៅលើសហព្រះរាជអាជ្ញា ក្នុងការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង នូវសម្ភារៈណាមួយដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន ដែលអាចជានត្ថិភាពនៃពិរុទ្ធ ឬសម្រាលពិរុទ្ធភាពរបស់ជនជាប់ចោទ ឬអាចមានឥទ្ធិពលទៅលើភាពជឿជាក់បាននៃភ័ស្តុតាង”[5]។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំថា សហព្រះរាជអាជ្ញាដំបូងត្រូវដាក់សំណើសុំបង្ហាញរបស់ខ្លួនទៅអង្គជំនុំជម្រះដោយប្តឹងពីភ័ស្តុតាងដែលខ្លួនចង់ដាក់បង្ហាញ បន្ទាប់មកទើបដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សុំឱ្យទទួលយកឯកសារនោះ ទុកជាការអនុម័តសម្រាប់ការដាក់បង្ហាញឯកសារ[6]។

4. អង្គជំនុំជម្រះសាលាដំបូងពីមុនធ្លាប់បានបង្គាប់ថា គ្រប់ការដាក់បង្ហាញឯកសារទាំងអស់ ពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២ គម្បីដាក់ និងជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងជាបណ្តោះអាសន្នដោយឈរលើមូលដ្ឋានសម្ងាត់បំផុត និងថាបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការកំណត់ចំពោះឯកសារនោះថាតើ គម្បីដាក់ចំណាត់ថ្នាក់ឡើងវិញថា សម្ងាត់ ឬក៏អត់[7]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីកំណត់ហេតុដែលមាននៅក្នុង **ឧបសម្ព័ន្ធ ១** ដោយឈរលើមូលដ្ឋានសម្ងាត់បំផុត។

5. សចសអ ក្នុងពេលថ្មីៗនេះ បានធ្វើការកែប្រែលើការដាក់កម្រិត និងបែបបទជាច្រើន សម្រាប់អនុវត្តចំពោះឯកសារនានាដែលបានដាក់បង្ហាញពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង

---

[4] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី “ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២”, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២។

[5] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី “ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២”, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២, ត្រង់ទំព័រទី១។

[6] **E127/7/1** ព័ត៌មានពាក់ព័ន្ធនឹងចម្លើយសាក្សីសំណុំរឿង០០៣ និងសំណុំរឿង០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង០០២, ១៦ សីហា ២០១៣, កថាខណ្ឌ២។

[7] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី “ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២”, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២, ត្រង់ទំព័រទី១។

០០២[8]។ ការអនុញ្ញាតស្តីពីការដាក់ឯកសារ ពេលនេះ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចខាងក្រោមៈ

ក. រាល់សម្ភារៈឯកសារទាំងអស់ត្រូវចាត់ទុកថាជាឯកសារសម្ងាត់។

ខ. សម្ភារៈត្រូវតែបំលែងតាមអេឡិចត្រូនិកទៅជាទម្រង់មួយដែលមានសញ្ញា (watermark) មិនអាចលុបជ្រះជាអក្សរក្រោម (sub-script) នៅលើទំព័រនិមួយៗនៃគ្រប់ឯកសារទាំងអស់សម្រាប់ភាគីទទួលនិមួយៗ។

គ. កំណត់ហេតុនៃការស្តាប់ចម្លើយ ត្រូវតែផ្តល់ជូនទៅក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងពីរ មេធាវីប្រចាំការរបស់ ខៀវ សំផន ("មេធាវីប្រចាំការ") និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសំណៅអេឡិចត្រូនិកដែលមានសញ្ញា watermark សម្រាប់ភាគីនិមួយៗ។

ឃ. កសព ត្រូវតែបង្ហាញឯកសារក្នុងរបៀបមួយដែលភាគីនិមួយៗ អាចចូលពិនិត្យមើលបានតែតាមរយៈសំណៅអេឡិចត្រូនិកដែលមានសញ្ញា watermark សម្រាប់ភាគីនិមួយៗតែប៉ុណ្ណោះ។

ង. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបង្ហាញសម្ភារៈដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ឲ្យទៅតែសមាជិកណានៅក្នុងក្រុមការងាររបស់ខ្លួនដែលទទួលបានការងារជាផ្លូវការតាមវិធានផ្ទៃក្នុង ២២(៥) និង ១២*ស្ទួនពីរ(៤)* ព្រមទាំងកម្មសិក្សាការីដែលទទួលបានការចាត់តាំងផ្លូវការតែប៉ុណ្ណោះ។

ច. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនអនុញ្ញាតឲ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ថតចម្លងសំណៅថតចម្លង

[8] សំណុំរឿង 004-**D193/19** ដីកាសម្រេចកែប្រែដីកាសម្រេច D193/4, D193/6, D193/8, D193/10, D193/11, D193/13, D193/15 និង D193/16 លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៅក្នុងសំណុំរឿង ០០២/០២, ១៣ មីនា ២០១៥។

នៃឯកសារដើម ក្រៅពីគោលបំណងប្រើប្រាស់ផ្ទៃក្នុងដែលបានផ្តល់ជូនខ្លួនពីសមាជិកក្រុមការងាររបស់ខ្លួន ដែលត្រូវបានណែនាំ ឬអនុញ្ញាតឲ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់។

ឆ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរក្សាកំណត់ហេតុក្នុងទម្រង់មួយដែលអាចពិនិត្យឡើងវិញ ក្នុងសំណៅមួយដែលអាចបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ថតចម្លងសំណៅថតចម្លងសម្រាប់ប្រើប្រាស់ផ្ទៃក្នុង។

ជ. ក្នុងករណីដែលសម្ភារៈដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវបានទទួលយកជាភ័ស្តុតាងក្នុងសំណុំរឿង០០២/០២ សម្ភារៈនេះត្រូវចាត់ទុកថាជាឯកសារសម្ងាត់។

ឈ. គ្មានសម្ភារៈណាមួយដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវផ្សព្វផ្សាយដល់សាធារណជនឡើយ ទោះក្នុងទម្រង់ណាមួយ ឬតាមរយៈរូបភាពណាមួយនៃប្រព័ន្ធផ្សព្វផ្សាយអ្វីក៏ដោយ។

ញ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីសំណៅគ្មានការអនុញ្ញាតណាមួយនៃសម្ភារៈដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ គាត់ត្រូវចាត់វិធានការទាំងអស់ភ្លាមៗ ដើម្បីរក្សាសុវត្ថិភាពសំណៅនោះ និងប្រគល់សំណៅនោះជូន សចស វិញ ហើយ

ដ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភបំពានលក្ខខណ្ឌ និងការដាក់កំហិតទាំងនេះ គាត់ត្រូវរាយការណ៍អំពីការរំលោភបំពានបែបនេះជូន សចស។

6. ដើម្បីអនុវត្តតាមការដាក់កំហិតទាំងនេះ សហព្រះរាជអាជ្ញានឹងធ្វើយ៉ាងណាឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា មេធាវីការពារក្តី ខៀវ សំផន និងមេធាវីប្រចាំការរបស់ ខៀវ សំផន បានទទួលសម្ភារៈទាំងនេះតាមអេឡិចត្រូនិក តាមរយៈហ្វូលឌ័ររួមឲ្យបានឆាប់តាមដែលអាចធ្វើបាន។

## II. ដំណោះស្រាយដែលស្នើឡើង

7. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយក និងដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២ នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីដូចបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ព័ន្ធ ១**៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៥ | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |